ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

នាយកដ្ឋានថវិកា

# គោលការណ៍ណែនាំ

# ស្តីពី

# ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា

រៀបចំកែសម្រួលថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ២០១០

រៀបចំ និងតាក់តែងដោយក្រុមការងារសមាហរណកម្ម និងភាពគ្រប់ជ្រុងជ្រោយថវិកា របស់នាយកដ្ឋានថវិកា

ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

# មាតិកា


ផ្នែកទី ១: សេចក្ដីផ្ដើម..................................................ទំព័រ ៣

១.១ និយមន័យនៃផែនការយុទ្ធសាស្ត្រថវិកា..................................ទំព័រ ៥

១.២ គោលបំណងនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា........................ទំព័រ ៥

១.៣ រចនាសម្ព័ន្ធនៃផែនការយុទ្ធសាស្ត្រថវិកា..................................ទំព័រ ៧

ផ្នែកទី ២: ដំណើរការនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា.........................ទំព័រ ៨

២.១ ការកំណត់ពីគោលបំណងគោលនយោបាយ....................................ទំព័រ ៩

២.២ ការរៀបចំកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាព.................................ទំព័រ ១០

២.៣ ការកំណត់សូចនាករ និងគោលដៅសូចនាករ..................................ទំព័រ ១១

២.៤ ការកំណត់ធនធាន..........................................................ទំព័រ ១៧

ផ្នែកទី ៣: ការត្រួតពិនិត្យ និងវាយតម្លៃផែនការយុទ្ធសាស្ត្រថវិកា....................ទំព័រ ១៩

៣.១ ការកំណត់គោលបំណងគោលនយោបាយ......................................ទំព័រ ២០

៣.២ ការរៀបចំកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាព.................................ទំព័រ ២២

៣.៣ ការកំណត់សូចនាករ និងគោលដៅសូចនាករ..................................ទំព័រ ២៣

៣.៤ ការកំណត់ធនធាន..........................................................ទំព័រ ២៥

ផ្នែកទី ៤: ឧបសម្ព័ន.........................................................ទំព័រ ២៨

ឧបសម្ព័នទី ១: ទម្រង់ និងបែបបទសម្រាប់រៀបចំផែនការយុទ្ធសាស្ត្រថវិកា.........ទំព័រ ២៩

ឧបសម្ព័នទី ២: ទម្រង់ និងបែបបទសម្រាប់ត្រួតពិនិត្យ និង វាយតម្លៃ
ផែនការយុទ្ធសាស្ត្រថវិកា.....................................................ទំព័រ ៣៤

# ផ្នែកទី ១៖

# សេចក្ដីផ្ដើម

ចាប់តាំងពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការ ជាលើកដំបូងនៅថ្ងៃទី ០៥ ខែ ធ្នូ ២០០៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បាន និង កំពុងធ្វើការកែទម្រង់លើគ្រប់ផ្នែក ហើយការកែទម្រង់លើការរៀបចំថវិកាជាផ្នែកមួយដ៏សំខាន់ និង កំពុងដើរតួនាទីយ៉ាងសកម្មនៅក្នុងការធានាឱ្យបាននូវប្រសិទ្ធិភាពនៃការគ្រប់គ្រង និង ការប្រើប្រាស់ធនធានសាធារណៈ ។ ផ្តើមចេញពីការកែទម្រង់ដ៏ស៊ីជម្រៅនេះ និងដោយការមើលឃើញពីភាពទន់ខ្សោយនៃការផ្សារភ្ជាប់ថវិកាទៅនឹងទិសដៅគោលនយោបាយរបស់រាជរដ្ឋាភិបាល នោះការរៀបចំផែនការយុទ្ធសាស្ត្រថវិកាត្រូវបានដាក់ឱ្យអនុវត្ត នៅក្នុងឆ្នាំ ២០០៧ ដែលគ្រប់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ត្រូវរៀបចំនៅក្នុងដំណាក់កាលទី ១ នៃការរៀបចំថវិកាប្រចាំឆ្នាំ គឺក្នុងចន្លោះខែមេសា និង ឧសភា ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវចេញសារាចរណែនាំរៀបចំផែនការយុទ្ធសាស្ត្រថវិកានេះ នៅដើមខែមេសា ។

យោងតាមមាត្រាទី ៣៩ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដំណើរការនៃការរៀបចំថវិកាប្រចាំឆ្នាំចែកចេញជា ៣ ដំណាក់កាល ដូចខាងក្រោមៈ

**ដំណាក់កាលទី ១: ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ពីខែ មីនា ដល់ខែ ឧសភា**

- នៅសប្តាហ៍ទី ១ នៃខែមីនា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរៀបចំក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម
- នៅសប្តាហ៍ទី ១ នៃខែមេសា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវចេញសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា
- ត្រឹមថ្ងៃទី ១៥ ខែ ឧសភា គ្រប់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញរាជធានី-ខេត្តត្រូវផ្ញើផែនការយុទ្ធសាស្ត្រថវិកា មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា)

**ដំណាក់កាលទី ២: ការរៀបចំកញ្ចប់ថវិកាពីខែ មិថុនា ដល់ខែ កញ្ញា**

- នៅសប្តាហ៍ទី ១ នៃខែមិថុនា ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវចេញសារាចរណែនាំស្តីពីបច្ចេកទេសនៃការរៀបចំគម្រោងថវិកា
  (សារាចរណែនាំស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់ គ្រងប្រចាំឆ្នាំ)
- ត្រឹមថ្ងៃទី ១៥ ខែ កក្កដា គ្រប់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញរាជធានី-ខេត្ត ត្រូវផ្ញើគម្រោងថវិកាប្រចាំឆ្នាំ មកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា)
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) រៀបចំប្រជុំពិភាក្សាគម្រោងថវិកាប្រចាំឆ្នាំកំរិតជំនាញ ចាប់ពីដើមសប្តាហ៍ទី ៣ ដល់ សប្តាហ៍ទី ៤ នៃខែកក្កដា និង កំរិតថ្នាក់ដឹកនាំនៅក្នុងខែសីហា ។

- នៅក្នុងខែកញ្ញាទាំងមូល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) ត្រូវរៀបចំបូកសរុបគម្រោងថវិកាប្រចាំឆ្នាំ ហើយរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុប្រចាំឆ្នាំ ជាមួយនឹងកំណត់បង្ហាញនៃសេចក្តីព្រាងច្បាប់ ។

**ដំណាក់កាលទី ៣: ការអនុម័តថវិកា ពីខែ តុលា ដល់ខែ ធ្នូ**

- នៅសប្តាហ៍ទី ១ នៃខែតុលា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបញ្ជូនសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុប្រចាំឆ្នាំ ជាមួយនឹងកំណត់បង្ហាញនៃសេចក្តីព្រាងច្បាប់នេះ ដើម្បីដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យ និងសម្រេច ។
- នៅសប្តាហ៍ទី ១ នៃខែវិច្ឆិកា រាជរដ្ឋាភិបាល ត្រូវបញ្ជូនសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុប្រចាំឆ្នាំជាមួយនឹងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងច្បាប់នេះ ដើម្បីដាក់ជូនរដ្ឋសភាពិនិត្យ និង អនុម័ត ។
- នៅសប្តាហ៍ទី ១ នៃខែធ្នូ រដ្ឋសភាត្រូវបញ្ជូនច្បាប់ស្តីពីហិរញ្ញវត្ថុប្រចាំឆ្នាំដែលបានអនុម័ត ទៅឱ្យព្រឹទ្ធសភា ។
- ច្បាប់ស្តីពីហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវបានអនុម័តជាស្ថាពរនៅមុនថ្ងៃទី ២៥ ខែ ធ្នូ ។

## ១.១ និយមន័យនៃផែនការយុទ្ធសាស្ត្រថវិកា

ផែនការយុទ្ធសាស្ត្រថវិកា ជាផែនការថវិការយៈពេលមធ្យម (៣ឆ្នាំ) ដោយឆ្លុះបញ្ចាំងពីគោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញរាជធានី-ខេត្ត ការកសាងកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាព ដើម្បីអនុវត្ត និងការកំណត់សូចនាករ និងគោលដៅសូចនាករសម្រាប់វាស់វែងការអនុវត្ត ។ ផែនការនេះទាមទារនូវការកំណត់ធនធានទាំងធនធានចរន្ត និង ធនធានមូលធន ដែលត្រូវការ និង ប្រើប្រាស់ សម្រាប់ឆ្នាំថវិកាកំពុងរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងពីរឆ្នាំបន្ទាប់របស់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ។

## ១.២ គោលបំណងនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា

ផែនការយុទ្ធសាស្ត្រថវិកា គឺមានគោលបំណងផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល ដើម្បីធានាឱ្យបាននូវការគ្រប់គ្រង និង ប្រើប្រាស់ធនធានសាធារណៈប្រកបដោយប្រសិទ្ធភាព និង ភាពស័ក្តសិទ្ធ ។ ម្យ៉ាងទៀត ផែនការយុទ្ធសាស្ត្រថវិកាផ្តល់ជាមូលដ្ឋានដល់ការរៀបចំថវិកាកម្មវិធី ហើយក៏ជាឧបករណ៍សម្រាប់ការធ្វើសមាហរណកម្មថវិការវាងថវិកាចរន្ត និង ថវិកាមូលធន ទាំងថវិការដ្ឋ និងថវិកាដៃគូអភិវឌ្ឍន៍ ដែលជាគោលដៅនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈ ។

ផែនការយុទ្ធសាស្ត្រថវិកានឹងត្រូវធ្វើសមាហរណកម្មជាមួយក្របខណ្ឌចំណាយរយៈពេលមធ្យមសម្រាប់ជាឧបករណ៍ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និង សម្រាប់ជាធាតុចូលដល់ការវិភាជន៍ថវិកាប្រចាំឆ្នាំប្រកបដោយប្រសិទ្ធភាព និង ស័ក្តិសិទ្ធិ ពីព្រោះ ក្របខណ្ឌចំណាយរយៈពេលមធ្យមត្រូវបានរៀបចំឡើងតាមអភិក្រមពី

លើចុះក្រោមនៅក្នុងការកំណត់កញ្ចប់ថវិកាទៅតាមវិស័យ ដោយផ្អែកលើក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច និង អាទិភាពគោលនយោបាយ រីឯផែនការយុទ្ធសាស្ត្រថវិកាត្រូវបានរៀបចំឡើងតាមអភិក្រមពីក្រោមឡើងលើ ដោយបង្ហាញឱ្យឃើញពីតម្រូវការថវិកាជាក់ស្តែងតាមក្រសួង-ស្ថាប័ន និង វិស័យនៅក្នុងការអនុវត្តគោលនយោបាយអាទិភាពតាមវិស័យ ។

ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា នឹងដោះស្រាយបញ្ហាសំខាន់ ៤ ដូចខាងក្រោម:



## ១.៣ រចនាសម្ព័ន្ធនៃផែនការយុទ្ធសាស្ត្រថវិកា

ផែនការយុទ្ធសាស្ត្រថវិការួមមាន ៦ ផ្នែក គឺ:



# ផ្នែកទី ២៖

# ដំណើរការនៃការរៀបចំ

# ផែនការយុទ្ធសាស្ត្រថវិកា

ដើម្បីឱ្យការរៀបចំផែនការយុទ្ធសាស្ត្រថវិកាបានល្អ និង មានសង្គតិភាព គ្រប់ក្រសួង-ស្ថាប័ន និង គ្រប់មន្ទីរជំនាញរាជធានី-ខេត្ត ត្រូវរៀបចំទៅតាមទម្រង់ និងបែបបទដែលរៀបចំឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដូចមាននៅក្នុងផ្នែកទី ៣ នៃគោលការណ៍ណែនាំនេះ ។ កត្តាចាំបាច់ដែលមិន អាចខ្វះបាននៅក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា គឺ ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ត្រូវបង្កើតក្រុមការងារថវិកាដែលមានសមាសភាពចូលរួមពីផ្នែកផែនការ ផ្នែកហិរញ្ញវត្ថុ និងផ្នែកគ្រប់គ្រងគម្រោង និងគួរដឹកនាំដោយថ្នាក់ដឹកនាំទទួលបន្ទុកផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ ហើយក្រុមការងារនេះត្រូវរៀបចំយន្តការការងារឱ្យបានច្បាស់លាស់ ដើម្បីធានាបាននូវនិរន្តរភាព និង ប្រសិទ្ធភាពការងារ ។

ការបកស្រាយ និង ពន្យល់ពីដំណើរការនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកាខាងក្រោមនេះ គឺផ្អែកទៅតាមឧបសម្ព័ន្ធទី ១ ស្តីអំពីទម្រង់ និងបែបបទសម្រាប់រៀបចំផែនការយុទ្ធសាស្ត្រថវិកា នៅក្នុងផ្នែកទី ៤ នៃគោលការណ៍ណែនាំនេះ ។

## ២.១ ការកំណត់គោលបំណងគោលនយោបាយ

នៅក្នុងផ្នែកនេះ ក្រសួង-ស្ថាប័ន ត្រូវកំណត់គោលបំណងគោលនយោបាយរបស់ខ្លួន ដែលត្រូវសម្រេចឱ្យបាននៅក្នុងរយៈពេលវែង ដោយផ្អែកលើគោលនយោបាយតាមវិស័យ ដែលមាននៅក្នុងយុទ្ធសាស្ត្រចតុកោណ ហើយដែលត្រូវបានរៀបចំនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ មន្ទីរជំនាញ រាជធានី-ខេត្តក្រោមឱវាទ ត្រូវផ្អែកលើគោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័នដែលជាអាណាព្យាបាល ធ្វើជាមូលដ្ឋានក្នុងការជ្រើសរើសគោលបំណងគោលនយោបាយឱ្យមានសង្គតិភាពជាមួយតម្រូវការតាមភូមិសាស្ត្ររបស់ខ្លួន ។ ដ្យាក្រាមខាងក្រោមបង្ហាញអំពីដំណើរការនៃការកំណត់គោលបំណងគោលនយោបាយ ។



| ឧទាហរណ៍ពីគោលបំណងគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា |
|---|
| • ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌ |
| • បង្កើនប្រសិទ្ធភាព និង គុណភាពសេវាអប់រំ |
| • អភិវឌ្ឍស្ថាប័ន និង កសាងសមត្ថភាពសម្រាប់ធ្វើវិមជ្ឈការ |

ការកំណត់គោលបំណងគោលនយោបាយដូចបានបង្ហាញក្នុងតារាងទី ២ នេះ គឺក្រសួងអប់រំ យុវជន និងកីឡា បាន ដកស្រង់ពីផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ ២០០៩-២០១៣។

## ២.២ ការរៀបចំកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាព

កម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាព ត្រូវបានរៀបចំឡើងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដែលជាយុទ្ធសាស្ត្រដើម្បីអនុវត្តយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ហើយការរៀបចំកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពនេះ គឺត្រូវធ្វើយ៉ាងណាឱ្យឆ្លើយតបទៅនឹងគោលបំណងគោលនយោបាយដែលបានកំណត់ ។ ការរៀបចំកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពនេះ ក៏ត្រូវមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដោយរួមមានទាំងកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាព ដែលផ្តល់ហិរញ្ញប្បទានដោយថវិការដ្ឋទាំងថវិកាកម្មវិធី និងមិនមែនកម្មវិធី និងហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ ។

កម្មវិធី ឬយុទ្ធសាស្ត្រអាទិភាព គឺជាវិធីសាស្ត្រក្នុងការអនុវត្តដើម្បីសម្រេចបាននូវគោលបំណងគោលនយោបាយដែលបានកំណត់ ហើយកម្មវិធីសំដៅទៅលើក្រសួង-ស្ថាប័នដែលអនុវត្តថវិកាកម្មវិធី និង កម្មវិធីដែលផ្តល់ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ ។ ដូចនេះ ក្រសួង-ស្ថាប័នខ្លះអាចមានទាំងកម្មវិធី និងយុទ្ធសាស្ត្រអាទិភាព ដោយឡែកក្រសួង-ស្ថាប័នខ្លះទៀតមិនមានកម្មវិធីទេ តែមានជាយុទ្ធសាស្ត្រអាទិភាព ។

មន្ទីរជំនាញរាជធានី-ខេត្ត ត្រូវយកកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពដែលរៀបចំឡើងដោយក្រសួង-ស្ថាប័ន ដែលជាអាណាព្យាបាល ធ្វើជាមូលដ្ឋានក្នុងការរៀបចំកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពឱ្យមានសង្គតភាពជាមួយតម្រូវការតាមភូមិសាស្ត្ររបស់ខ្លួន ។

| ឧទាហរណ៍ពីការរៀបចំកម្មវិធីរបស់ក្រសួងអប់រំ យុវជន និងកីឡា | |
|---|---|
| **គោលបំណងគោលនយោបាយ** | **កម្មវិធី** |
| • ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌ | • ការអភិវឌ្ឍអប់រំចំណេះទូទៅ និង អប់រំក្រៅប្រព័ន្ធ |
| • បង្កើនប្រសិទ្ធភាព និង គុណភាពសេវាអប់រំ | • ការអភិវឌ្ឍអប់រំ បណ្តុះបណ្តាល បច្ចេកទេស ឧត្តមសិក្សា និង ស្រាវជ្រាវវិទ្យាសាស្ត្រ |
| • អភិវឌ្ឍស្ថាប័ន និង កសាងសមត្ថភាពសម្រាប់ធ្វើវិមជ្ឈការ | • ការអភិវឌ្ឍន៍វិស័យអប់រំកាយ និងកីឡា<br>• ការអភិវឌ្ឍន៍យុវជន<br>• ការគាំទ្រ និងការគ្រប់គ្រងសេវាអប់រំ និងអភិបាលកិច្ចល្អ |

__ការណែនាំក្នុងការបំពេញតារាង ៣.១ នៃឧបសម្ព័ន្ធទី ១:__

- កូលោន **គោលបំណងគោលនយោបាយ** តម្រូវឱ្យរៀបរាប់ពីគោលបំណងគោលនយោបាយ ដូចដែលបានបង្ហាញនៅក្នុងតារាងទី ២ ខាងលើ
- កូលោន **កម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាព** តម្រូវឱ្យរៀបរាប់ពីកម្មវិធី ឬ យុទ្ធសាស្ត្រអាទិភាព

  លេខ ១.១: មានន័យថា កម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពទី ១ របស់គោលបំណងគោលនយោបាយទី ១

  លេខ ១.២: មានន័យថា កម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពទី ២ របស់គោលបំណងគោលនយោបាយទី ១

  លេខ ២.១: មានន័យថា កម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពទី ១ របស់គោលបំណងគោលនយោបាយទី ២
- កូលោន **រយៈពេលអនុវត្ត** តម្រូវឱ្យកំណត់រយៈពេលដែលត្រូវការដើម្បីអនុវត្តកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាព ដោយបញ្ជាក់ពីឆ្នាំចាប់ផ្តើម និងឆ្នាំបញ្ចប់ (ឧទាហរណ៍ បើសិនកម្មវិធីមួយ ត្រូវការរយៈពេល ៥ ឆ្នាំ ដើម្បីអនុវត្ត ដោយចាប់ពីឆ្នាំ ២០០៨ នោះត្រូវសរសេរ ***២០០៨-២០១២***)
- កូលោន **តម្រូវការឥណទានសរុប** តម្រូវឱ្យព្យាករណ៍ឥណទានដែលត្រូវការសម្រាប់អនុវត្តកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាព ចាប់ពីឆ្នាំដំបូង រហូតដល់ឆ្នាំបញ្ចប់
- កូលោន **ឥណទានបានអនុវត្តកន្លងមក** តម្រូវឱ្យគណនាឥណទានដែលបានអនុវត្តរួចហើយ ដោយគិតចាប់ពីឆ្នាំដំបូងនៃការអនុវត្តកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាព រហូតមកដល់ឆ្នាំបច្ចុប្បន្ន **(n)**
- កូលោន **តម្រូវការឥណទានបន្ត** តម្រូវឱ្យគណនាតម្រូវការឥណទានបន្តដែលជាផលដករវាងតម្រូវការឥណទានសរុប ជាមួយនឹងឥណទានបានអនុវត្តកន្លងមក និងការគ្រោង និងព្យាករណ៍តម្រូវការឥណទានសម្រាប់ឆ្នាំបន្ទាប់ទី១ ឆ្នាំបន្ទាប់ទី២ និង ឆ្នាំបន្ទាប់ទី៣

## ២.៣ ការកំណត់សូចនាករ និងគោលដៅសូចនាករ

នៅក្នុងផ្នែកនេះ បង្ហាញអំពីការកំណត់សូចនាករ និងគោលដៅសូចនាករ ដើម្បីតាមដានវឌ្ឍនភាព និងវាយតម្លៃការអនុវត្តកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពនីមួយៗ ។ ដូចនេះ ក្រោយពីបានកំណត់កម្មវិធី ឬ/និងយុទ្ធសាស្ត្រ អាទិភាពដើម្បីសម្រេចបាននូវគោលបំណងគោលនយោបាយដែលបានកំណត់រួចហើយ ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញ រាជធានី-ខេត្ត ត្រូវយកចិត្តទុកដាក់លើការងារ ២ ជំហាន ដូចខាងក្រោម:




**ជំហានទី ១: ការកំណត់សូចនាករ**

សូចនាករ គឺជារង្វាស់ដែលអាចកំណត់គោលដៅសមិទ្ធកម្មដើម្បីតាមដានវឌ្ឍនភាព និង សមិទ្ធិផលនៃការអនុវត្តកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាព ហើយសូចនាករមានលក្ខណៈជាបរិមាណ និងជាគុណភាព ។ នៅក្នុងការកំណត់សូចនាករ ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញរាជធានី-ខេត្ត ត្រូវកំណត់ទាំងសូចនាករលទ្ធផលក្នុងឆ្នាំ និងសូចនាករលទ្ធផលចុងក្រោយរបស់កម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពនីមួយៗ ។ ដើម្បីកំណត់សូចនាករឱ្យបានល្អត្រូវ ផ្តោតលើកត្តាសំខាន់ ៧ ដូចខាងក្រោម:

- **ភាពគ្រប់ជ្រុងជ្រោយ:** សូចនាករត្រូវតែមានភាពគ្រប់ជ្រុងជ្រោយ និងគ្រប់គ្រាន់ដែលឆ្លើយតបទៅនឹងកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាព និង គោលបំណងគោលគោលនយោបាយដែលបានកំណត់
- **មានន័យគ្រប់គ្រាន់ និងងាយយល់:** សូចនាករត្រូវមានភាពងាយយល់ និង មានប្រយោជន៍ដល់អ្នកគ្រប់គ្រង និង អ្នកនយោបាយ
- **ភាពជឿទុកចិត្ត:** សូចនាករត្រូវមានទិន្នន័យ និង ព័ត៌មានគ្រប់គ្រាន់ដែលអាចធ្វើជាមូលដ្ឋានបាន
- **ភាពសាមញ្ញ:** សូចនាករត្រូវមានភាពសាមញ្ញដែលផ្តល់ភាពងាយស្រួលក្នុងការគណនា និង បកស្រាយ

- **ភាពត្រឹមត្រូវៈ** សូចនាករត្រូវមានភាពគ្រប់គ្រាន់ដែលធានាបាននូវសុក្រឹត្យភាពនៃការវាយតម្លៃអំពីលទ្ធផលក្នុងឆ្នាំ និងលទ្ធផលចុងក្រោយ ។
- **ភាពផ្ទៀងផ្ទាត់ៈ** សូចនាករត្រូវតែមានព័ត៌មានដែលអាចធ្វើការផ្ទៀងផ្ទាត់ និងត្រួតពិនិត្យបាន ។
- **ប្រសិទ្ធភាពៈ** ការប្រមូលទិន្នន័យដែលទាក់ទងនឹងសូចនាករត្រូវតែចំណាយតិច ហើយបានទាន់ពេលវេលា ។

សូចនាករលទ្ធផលក្នុងឆ្នាំ គឺជារង្វាស់ដែលអាចកំណត់គោលដៅសមិទ្ធកម្មនៃការអនុវត្តកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពនីមួយៗនៅក្នុងរយៈពេលជាក់លាក់មួយ (មិនលើសពីមួយឆ្នាំ) ។ រីឯ សូចនាករលទ្ធផលចុងក្រោយ គឺជារង្វាស់ដែលអាចកំណត់គោលដៅសមិទ្ធកម្មចុងក្រោយដែលជាលទ្ធផលបង្កើតឡើងដោយលទ្ធផលក្នុងឆ្នាំនៃការអនុវត្តកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាព ក្នុងរយៈពេលមធ្យម និងវែង (លើសពីមួយឆ្នាំ) ។

កម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពនីមួយៗ អាចមានសូចនាករច្រើន ប៉ុន្តែក្រសួង-ស្ថាប័ន និង មន្ទីរជំនាញរាជធានី-ខេត្ត ត្រូវជ្រើសរើសសូចនាករក្នុងកំរិតមួយសមស្រប និង គ្រប់គ្រាន់ដែលធានានូវការសម្រេចបាននៃការអនុវត្តកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាព ។

| **ឧទាហរណ៍ពីការកំណត់សូចនាករលទ្ធផលក្នុងឆ្នាំ** | | |
|---|---|---|
| **កម្មវិធី** | **សូចនាករលទ្ធផលក្នុងឆ្នាំ** | **ការវាយតម្លៃលើភាពគ្រប់គ្រាន់របស់សូចនាករ** |
| ការកែលម្អ និងលើកកម្ពស់គុណភាពអប់រំនៅឧត្តមសិក្សា | សូចនាករទី ១: ចំនួនគ្រូនៅឧត្តមសិក្សាដែលទទួលបានការបណ្តុះបណ្តាល | អាចប្រមូលទិន្នន័យបានគ្រប់គ្រាន់ |
| | សូចនាករទី ២: %នៃនិស្សិតបោះបង់ការសិក្សាថយចុះ | អាចប្រមូលទិន្នន័យបានគ្រប់គ្រាន់ |
| | សូចនាករទី ៣: ចំនួននិស្សិតរៀនត្រួតឆ្នាំនៅឧត្តមសិក្សាថយចុះ | អាចប្រមូលទិន្នន័យបានគ្រប់គ្រាន់ |
| | សូចនាករទី ៤: ចំនួននិស្សិតដែលរៀននៅផ្ទះ និងខិតខំស្រាវជ្រាវបន្ថែម កើនឡើង | ពិបាកក្នុងការប្រមូលទិន្នន័យព្រោះទាមទារឱ្យមានការធ្វើអង្កេត |
| | សូចនាករទី ៥: មានបណ្ណាល័យ និង ឯកសារស្រាវជ្រាវគ្រប់គ្រាន់ | អាចប្រមូលទិន្នន័យបានគ្រប់គ្រាន់ |

| ឧទាហរណ៍ពីការកំណត់សូចនាករលទ្ធផលចុងក្រោយ | | |
|---|---|---|
| **កម្មវិធី** | **សូចនាករលទ្ធផលចុងក្រោយ** | **ការវាយតម្លៃលើភាពគ្រប់គ្រាន់របស់សូចនាករ** |
| ការកែលម្អ និង លើកកម្ពស់គុណភាពអប់រំនៅឧត្តមសិក្សា | សូនាករទី ១: %នៃការមានការងាររបស់និស្សិតដែលបញ្ចប់ការសិក្សាកើនឡើង | ពិបាកក្នុងការប្រមូលទិន្នន័យព្រោះទាមទារឱ្យមានការធ្វើអង្កេត |
| | សូចនាករទី ២: %នៃនិស្សិតដែលបានបញ្ចប់ការសិក្សាប្រកបដោយជោគជ័យ កើនឡើង | អាចប្រមូលទិន្នន័យបានគ្រប់គ្រាន់ |
| | សូចនាករទី ៣: %នៃនិស្សិតដែលទទួលបានអាហារូបករណ៍ទៅសិក្សាបន្តនៅបរទេសកើនឡើង | ពិបាកក្នុងការប្រមូលទិន្នន័យព្រោះទាមទារឱ្យមានការធ្វើអង្កេត |

**ជំហានទី ២: ការកំណត់គោលដៅនៃសូចនាករដែលបានជ្រើសរើស**

ការងារបន្តទៀត គឺត្រូវកំណត់គោលដៅសូចនាករទាំងគោលដៅសូចនាករលទ្ធផលក្នុងឆ្នាំ និងគោលដៅសូចនាករលទ្ធផលចុងក្រោយ ដែលចាំបាច់ទាមទារឱ្យមានទំនាក់ទំនងគ្នា និងឆ្លើយតបគ្នាយ៉ាងមានប្រសិទ្ធភាព ដើម្បីធានានូវការសម្រេចបានគោលបំណងគោលនយោបាយដែលបានកំណត់នៅក្នុងរយៈពេលជាក់លាក់មួយ ។

គោលដៅសូចនាករលទ្ធផលក្នុងឆ្នាំ គឺការកំណត់គោលដៅជាបរិមាណ ឬ/និងជាគុណភាព ប្រចាំឆ្នាំ ដែលជាសមិទ្ធផលនៃការអនុវត្តកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពនីមួយៗ ។ រីឯ គោលដៅសូចនាករលទ្ធផលចុងក្រោយ គឺជាការកំណត់គោលដៅសមិទ្ធកម្មចុងក្រោយជាបរិមាណ ឬ/និងជាគុណភាពដែលជាលទ្ធផលបង្កើតឡើងដោយលទ្ធផលក្នុងឆ្នាំនៃការអនុវត្តកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពនីមួយៗ នៅក្នុងរយៈពេលមធ្យម និងវែង (លើសពី ១ ឆ្នាំ) ។

ការកំណត់គោលដៅសូចនាករ កត្តាចាំបាច់ និងសំខាន់បំផុត គឺត្រូវដឹងពីស្ថានភាពបច្ចុប្បន្នរបស់សូចនាករទាំងនោះ ដែលអាចទៅកំណត់គោលដៅដែលចង់បានដើម្បីឆ្លើយតបទៅនឹងគោលបំណងគោលនយោបាយ ដែលបានកំណត់ ហើយការកំណត់គោលដៅនេះ ចាំបាច់ត្រូវតែមានភាពសមស្រប និង ប្រាកដនិយមដែលអាចអនុវត្តបាន ។

| ឧទាហរណ៍ពីការកំណត់គោលដៅសូចនាករលទ្ធផលក្នុងឆ្នាំ | | | | |
|---|---|---|---|---|
| **សូចនាករលទ្ធផលក្នុងឆ្នាំ** | **ស្ថានភាពបច្ចុប្បន្ន** | **គោលដៅ ឆ្នាំ n+1** | **គោលដៅ ឆ្នាំ n+2** | **គោលដៅ ឆ្នាំ n+3** |
| សូចនាករទី ១: ចំនួនគ្រូនៅឧត្តមសិក្សាដែលទទួលបានការបណ្តុះបណ្តាល | គ្រូ ៣.០០០ នាក់ត្រូវការបណ្តុះបណ្តាល | គ្រូ ៥០០ នាក់ទទួលបានការបណ្តុះបណ្តាល | គ្រូ ៥០០ នាក់ទទួលបានការបណ្តុះបណ្តាល | គ្រូ ៥០០ នាក់ទទួលបានការបណ្តុះបណ្តាល |
| សូចនាករទី ២: %នៃនិស្សិតបោះបង់ការសិក្សាថយចុះ | មាននិស្សិតបោះបង់ការសិក្សា ៤០% | និស្សិតបោះបង់ការសិក្សាថយចុះមកនៅត្រឹម ៣០% | និស្សិតបោះបង់ការសិក្សាថយចុះមកនៅត្រឹម ២០% | និស្សិតបោះបង់ការសិក្សាថយចុះមកនៅត្រឹម ១០% |
| សូចនាករទី ៣: ចំនួននិស្សិតរៀនត្រួតឆ្នាំនៅឧត្តមសិក្សាថយចុះ | មាននិស្សិតរៀនត្រួតឆ្នាំ ២៥% | និស្សិតរៀនត្រួតឆ្នាំថយចុះមកនៅត្រឹម ២០% | និស្សិតរៀនត្រួតឆ្នាំថយចុះមកនៅត្រឹម ១០% | និស្សិតរៀនត្រួតឆ្នាំថយចុះមកនៅត្រឹម ៥% |
| សូចនាករទី ៤: ចំនួននិស្សិតដែលរៀននៅផ្ទះ និងខិតខំស្រាវជ្រាវបន្ថែម កើនឡើង | ? | ? | ? | ? |
| សូចនាករទី ៥: មានបណ្ណាល័យ និង ឯកសារស្រាវជ្រាវគ្រប់គ្រាន់ | បណ្ណាល័យ និង ឯកសារស្រាវជ្រាវអាចបំពេញតម្រូវការនិស្សិតត្រឹមតែ ៥០% | បណ្ណាល័យ និង ឯកសារស្រាវជ្រាវអាចបំពេញតម្រូវការនិស្សិតបាន ៦០% | បណ្ណាល័យ និង ឯកសារស្រាវជ្រាវអាចបំពេញតម្រូវការនិស្សិតបាន ៧០% | បណ្ណាល័យ និង ឯកសារស្រាវជ្រាវអាចបំពេញ តម្រូវការនិស្សិតបាន ៨០% |

| ឧទាហរណ៍ពីការកំណត់គោលដៅសូចនាករលទ្ធផលចុងក្រោយ | | |
|---|---|---|
| **សូចនាករលទ្ធផលចុងក្រោយ** | **ស្ថានភាពបច្ចុប្បន្ន** | **គោលដៅលទ្ធផលចុងក្រោយ** |
| សូនាករទី ១: %នៃការមានការងាររបស់និស្សិតដែលបញ្ចប់ការសិក្សាកើនឡើង | អត្រាមានការងារធ្វើរបស់និស្សិតដែលបានបញ្ចប់ការសិក្សាមានត្រឹមតែ ៣០% | អត្រាមានការងារធ្វើរបស់និស្សិតដែលបានបញ្ចប់ការសិក្សានឹងមាន ៧០% |
| សូចនាករទី ២: %នៃនិស្សិតដែលបានបញ្ចប់ការសិក្សាប្រកបដោយជោគជ័យកើនឡើង | ជារៀងរាល់ឆ្នាំនិស្សិតដែលបានបញ្ចប់ការសិក្សាប្រកបដោយជោគជ័យមានត្រឹមតែ ៦០% | និស្សិតដែលបានបញ្ចប់ការសិក្សាប្រកបដោយជោគជ័យនឹងកើនឡើងដល់ ៨០% |
| សូចនាករទី ៣: %នៃនិស្សិតដែលទទួលបានអាហារូបករណ៍ទៅសិក្សានៅបរទេសកើនឡើង | និស្សិតដែលទទួលបានអាហារូបករណ៍ទៅសិក្សានៅបរទេសមានត្រឹមតែ ១០% | និស្សិតដែលទទួលបានអាហារូបករណ៍ទៅសិក្សានៅបរទេសនឹងកើនឡើងដល់ ៤០% |

ការវាយតម្លៃពីការសម្រេចបាននូវគោលដៅលទ្ធផលចុងក្រោយគឺមានការលំបាក ដោយហេតុថាមានកត្តាខាងក្រៅផ្សេងៗទៀតដែលអាចមានផលប៉ះពាល់ជាវិជ្ជមាន ឬអវិជ្ជមានដល់គោលដៅលទ្ធផលចុងក្រោយនេះ ។ ឧទាហរណ៍ ផ្អែកតាមតារាងទី ០៧ ខាងលើ គោលដៅសូចនាករលទ្ធផលចុងក្រោយមួយ គឺ អត្រាមានការងាររបស់និស្សិតដែលបានបញ្ចប់ការសិក្សានឹងមាន ៧០% ករណីនេះ ការវាយតម្លៃពីការសម្រេចបាន ឬមិនបានរបស់គោលដៅសូចនាករលទ្ធផលចុងក្រោយដែលជាលទ្ធផលបង្កើតឡើងដោយលទ្ធផលក្នុងឆ្នាំនៃការអនុវត្តកម្មវិធីកែលម្អ និងលើកកម្ពស់គុណភាពអប់រំនៅឧត្តមសិក្សា គឺមានការលំបាក ពីព្រោះអាចមានកត្តាខាងក្រៅផ្សេងៗទៀតដែលជះឥទ្ធិពលដល់ការសម្រេចបាន ឬមិនបានរបស់គោលដៅសូចនាករនោះ ដូចជា ការប្រែប្រួលនូវកំណើនសេដ្ឋកិច្ច ដែលបណ្តាលមកពីកត្តាក្នុងស្រុក ឬក្រៅស្រុកដែលអាចជះឥទ្ធិពលវិជ្ជមាន ឬអវិជ្ជមានដល់ការវិនិយោគជាដើម ។

**<u>ការណែនាំក្នុងការបំពេញតារាង ៤.១ នៃឧបសម្ព័ន្ធទី ១:</u>**

- កូលោន **កម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាព** តម្រូវឱ្យរៀបរាប់កម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពនីមួយៗ
- កូលោន **ការកំណត់សូចនាករលទ្ធផលក្នុងឆ្នាំ និង លទ្ធផលចុងក្រោយ** តម្រូវអោយកំណត់រង្វាស់សម្រាប់លទ្ធផលក្នុងឆ្នាំ និងលទ្ធផលចុងក្រោយនៃការអនុវត្តកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាព។
- កូលោន **ស្ថានភាពបច្ចុប្បន្នសូចនាករលទ្ធផលក្នុងឆ្នាំ និង លទ្ធផលចុងក្រោយ** តម្រូវឱ្យបង្ហាញនូវស្ថានភាពបច្ចុប្បន្នរបស់សូចនាករលទ្ធផលក្នុងឆ្នាំ និងសូចនាករលទ្ធផលចុងក្រោយនីមួយៗដែលផ្តល់ជាមូលដ្ឋានក្នុងការកំណត់គោលដៅរបស់សូចនាករទាំងនោះ ។ ដូច្នេះការជ្រើសរើសសូចនាករ គឺជាកត្តាសំខាន់ ដោយហេតុថា សូចនាករមួយចំនួនពុំមានមូលដ្ឋានព័ត៌មានគ្រប់គ្រាន់ដែលអាចឱ្យដឹងពីស្ថានភាពបច្ចុប្បន្នរបស់វាបានទេ ។
- កូលោន **គោលដៅសូចនាករលទ្ធផលក្នុងឆ្នាំ** តម្រូវឱ្យកំណត់គោលដៅប្រចាំឆ្នាំរបស់សូចនាករនីមួយៗ ហើយការកំណត់គោលដៅនេះត្រូវមានភាពសមស្រប និង ប្រាកដនិយម ដែលអាចអនុវត្តបាន និង សម្រេចបាននូវគោលបំណងគោលនយោបាយដែលបានកំណត់។
- កូលោន **គោលដៅសូចនាករលទ្ធផលចុងក្រោយ** តម្រូវឱ្យកំណត់គោលដៅសមិទ្ធកម្មចុងក្រោយរបស់សូចនាករនីមួយៗ ហើយការកំណត់គោលដៅនេះ ត្រូវមានសង្គតិភាពទៅនឹងលទ្ធផលក្នុងឆ្នាំ និង ឆ្លើយតបទៅនឹងគោលបំណងគោលនយោបាយដែលបានកំណត់។

## ២.៤ ការកំណត់ធនធាន

### ២.៤.១ ការកំណត់តម្រូវការចំណាយ

ផ្អែកលើគោលបំណងគោលនយោបាយ និង កម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពដែលបានកំណត់ ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញរាជធានី-ខេត្ត ត្រូវកំណត់ពីតម្រូវការធនធានដើម្បីអនុវត្តកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពនីមួយៗ ដោយផ្តោតជាសំខាន់លើកត្តាមួយចំនួនដូចខាងក្រោម:

- ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈដែលបានកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដូចជាកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំ អត្រាអតិផរណាប្រចាំឆ្នាំ ជាដើម ។
- ការវាយតម្លៃការអនុវត្តចំណាយក្នុងរយៈកាលកន្លងមក និងការប៉ាន់ស្មានការអនុវត្តចំណាយក្នុងឆ្នាំកំពុងអនុវត្ត របស់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញរាជធានី-ខេត្ត នីមួយៗ
- ការកំណត់តម្រូវការធនធានទៅតាមឆ្នាំនីមួយៗ ត្រូវមានភាពជាក់ស្តែង និង សុក្រឹត្យ ដើម្បីឆ្លើយតបទៅតាមតម្រូវការរបស់កម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពនីមួយៗ ។

<u>**ការណែនាំក្នុងការបំពេញតារាង ៥.១ នៃឧបសម្ព័ន្ធទី ១:**</u>

- កូលោន **គោលបំណងគោលនយោបាយ/កម្មវិធី/យុទ្ធសាស្ត្រអាទិភាព/ប្រភេទចំណាយ** តម្រូវឱ្យវិភាជន៍ចំណាយរបស់កម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពនីមួយៗទៅតាមប្រភេទចំណាយចរន្ត និង មូលធន ហើយចំណាយចរន្តត្រូវចែកចេញជាចំណាយបន្ទុកបុគ្គលិក និង ក្រៅពីបន្ទុកបុគ្គលិក ។ ចំពោះចំណាយបន្ទុកបុគ្គលិកអាចមិនតម្រូវឱ្យវិភាជន៍ទៅតាមកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពនីមួយៗទេ ក្នុងករណីមិនអាចធ្វើទៅបាន។ ចំណាយមូលធនចែកចេញជា គម្រោងវិនិយោគ មូលនិធិបដិភាគដោយថវិការដ្ឋក្នុងការអនុវត្តគម្រោង មូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ និង ជំនួយបច្ចេកទេស ។
- កូលោន **ថវិការដ្ឋ** ជាតម្រូវការឥណទានពីថវិការដ្ឋក្នុងការអនុវត្តគោលបំណងគោលនយោ-បាយ និង កម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាព ។
- កូលោន **ថវិកាដៃគូអភិវឌ្ឍន៍** ជាតម្រូវការឥណទានដែលទទួលបានពីដៃគូអភិវឌ្ឍន៍ក្នុងការអនុវត្តគោលបំណងគោលនយោបាយ និងកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពណាមួយ ។
- កូលោន **ផ្សេងៗ** ជាតម្រូវការឥណទានដែលទទួលបានពីប្រភពផ្សេងៗទៀតក្រៅពីថវិការដ្ឋ និងពីដៃគូអភិវឌ្ឍន៍ក្នុងការអនុវត្តគោលបំណងគោលនយោបាយ និង កម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពណាមួយ ។

## ២.៤.២ ការគ្រោងចំណូល

នៅក្នុងផ្នែកនេះ ប្រសិនបើក្រសួង-ស្ថាប័ន និង មន្ទីរជំនាញរាជធានី-ខេត្ត ដែលមិនមានប្រភពចំណូល គឺពុំតម្រូវឱ្យរៀបចំឡើយ ដោយឡែកចំពោះក្រសួង-ស្ថាប័ន និង មន្ទីរជំនាញរាជធានី-ខេត្ត ដែលមានប្រភពចំណូល គឺត្រូវរៀបចំយុទ្ធសាស្ត្ររួមមានទាំងគោលនយោបាយ និង វិធានការសម្រាប់ពង្រឹងការគ្រប់គ្រង និង ប្រមូលចំណូល ។

នៅក្នុងការគ្រោងចំណូល ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញរាជធានី-ខេត្ត ត្រូវផ្អែកជាសំខាន់លើៈ

- គោលនយោបាយចំណូលរយៈពេលមធ្យម
- ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ
- យុទ្ធសាស្ត្រដែលបានរៀបចំ
- ការវាយតម្លៃការអនុវត្តប្រមូលចំណូលក្នុងឆ្នាំកន្លងទៅ និង ការប៉ាន់ស្មានការអនុវត្តប្រមូលចំណូលក្នុងឆ្នាំកំពុងអនុវត្ត

**ការណែនាំក្នុងការបំពេញតារាង ៥.២ នៃឧបសម្ព័ន្ធទី ១:**

- កូលោន **ប្រភេទចំណូល** តម្រូវឱ្យសរសេរនូវប្រភពចំណូលដែលស្ថិតក្រោមការគ្រប់គ្រង និង ប្រមូលដោយក្រសួង-ស្ថាប័ន និង មន្ទីរជំនាញរាជធានី-ខេត្ត ដោយចែកចេញជាពីរប្រភេទ គឺ ចំណូលពីប្រភពក្នុងស្រុក និងចំណូលពីប្រភពខាងក្រៅ ។ ចំណូលពីប្រភពក្នុងស្រុក រួមមាន ចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធ និង ចំណូលមូលធនក្នុងស្រុក ដែលជាប្រភពចំណូលផ្ទាល់របស់ ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញរាជធានី-ខេត្ត។ ចំណូលពីប្រភពខាងក្រៅ ជាប្រភេទចំណូលមូលធន ដែលទទួលបានពីដៃគូអភិវឌ្ឍន៍ ហើយមានពីរប្រភេទ គឺគម្រោងវិនិយោគ និងជំនួយបច្ចេកទេស ។ ប្រភេទចំណូលនេះ គឺត្រូវលំអិតទៅតាមឈ្មោះកម្មវិធី ឬ គម្រោងនីមួយៗ និងទៅតាមប្រភេទគម្រោងវិនិយោគ និង ជំនួយបច្ចេកទេស ។
- កូលោន **ច្បាប់ហិរញ្ញវត្ថុឆ្នាំ n** តម្រូវឱ្យបញ្ចូលនូវតណទានចំណូលដែលត្រូវប្រមូលនៅក្នុងឆ្នាំ n (គិតជាលានរៀល) ហើយដែលបានអនុម័តដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ n
- កូលោន **គ្រោងឆ្នាំបន្ទាប់ទី១ (n+1) គ្រោងឆ្នាំបន្ទាប់ទី២ (n+2) និង គ្រោងឆ្នាំបន្ទាប់ទី៣ (n+3)** តម្រូវឱ្យគ្រោងចំណូលនៅក្នុងឆ្នាំនីមួយៗ (គិតជាលានរៀល) ដែលរំពឹងថានឹងទទួលបានដោយផ្អែកលើយុទ្ធសាស្ត្រពង្រឹងការប្រមូលចំណូលដែលបានកំណត់ ។

# ផ្នែកទី ៣៖

# ការត្រួតពិនិត្យ និងវាយតម្លៃ

# ផែនការយុទ្ធសាស្ត្រថវិកា

នៅក្នុងខែមីនានៃឆ្នាំទីមួយៗ គ្រប់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ត្រូវរៀបចំត្រួតពិនិត្យ និងវាយតម្លៃផែនការយុទ្ធសាស្ត្រថវិកាដែលបានរៀបចំនៅក្នុងឆ្នាំមុន ទៅតាមទម្រង់បែបបទដែលមាននៅក្នុងឧបសម្ព័ន្ធទី ២ នៅក្នុងផ្នែកទី ៤ នៃគោលការណ៍ណែនាំនេះ ។

ការត្រួតពិនិត្យ និងវាយតម្លៃផែនការយុទ្ធសាស្ត្រថវិកានេះ នឹងជួយឱ្យក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត រកឃើញនូវចំណុចខ្វះខាតទាំងឡាយដើម្បីកែលម្អផែនការយុទ្ធសាស្ត្រថវិកាសម្រាប់ឆ្នាំបន្ទាប់ ដែលនឹងត្រូវរៀបចំនៅក្នុងខែមេសា ។ ផ្នែកដែលត្រូវត្រួតពិនិត្យ និងវាយតម្លៃ រួមមាន:

១. ការត្រួតពិនិត្យ និងវាយតម្លៃគោលបំណងគោលនយោបាយ

២. ការត្រួតពិនិត្យ និងវាយតម្លៃកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាព

៣. ការត្រួតពិនិត្យ និងវាយតម្លៃសូចនាករ និងគោលដៅសូចនាករ

៤. ការត្រួតពិនិត្យ និងវាយតម្លៃការកំណត់ធនធាន

នៅក្នុងផ្នែកនេះ នឹងផ្តល់នូវការណែនាំដែលទាក់ទងនឹងការត្រួតពិនិត្យ និងវាយតម្លៃតាមផ្នែកនីមួយៗដូចរៀបរាប់ខាងលើ ដែលមានខ្លឹមសារដូចតទៅ:

## ៣.១ ការត្រួតពិនិត្យ និងវាយតម្លៃគោលបំណងគោលនយោបាយ

គ្រប់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ត្រូវត្រួតពិនិត្យ និងវាយតម្លៃគោលបំណងគោលនយោបាយដែលបានរៀបចំនៅក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំមុន ដើម្បីកំណត់ពីសុពលភាពនៃគោលបំណងគោលនយោបាយនោះ ដែលនាំឱ្យមានការកែសម្រួលគោលបំណងគោលនយោបាយសម្រាប់រៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំបន្ទាប់ ។ ការត្រួតពិនិត្យ និងវាយតម្លៃនេះ ត្រូវផ្តោតទៅលើកត្តាដែលធ្វើឱ្យគោលបំណងគោលនយោ-បាយមានការផ្លាស់ប្តូរ ដែលកត្តាទាំងនោះ គឺ:

- ការផ្លាស់ប្តូរមុខងារ និងភារកិច្ចរបស់ស្ថាប័ន: ប្រសិនបើមានការផ្លាស់ប្តូរមុខងារ និងភារកិច្ច នោះចាំបាច់ត្រូវកំណត់គោលបំណងគោលនយោបាយឡើងវិញ ដើម្បីឱ្យស៊ីគ្នាជាមួយនឹងមុខងារ និងភារកិច្ចថ្មី ។
- ការផ្លាស់ប្តូរគោលនយោបាយតាមវិស័យ: ប្រសិនបើមានការផ្លាស់ប្តូរគោលនយោបាយតាមវិស័យរបស់ខ្លួននៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដែលជាលទ្ធផលនៃការផ្លាស់ប្តូរគោលនយោបាយនៅក្នុងយុទ្ធសាស្ត្រចតុកោណ ចាំបាច់ត្រូវកំណត់គោលបំណងគោលនយោបាយឡើងវិញដើម្បីឱ្យស៊ីគ្នាជាមួយនឹងគោលនយោបាយតាមវិស័យរបស់ខ្លួនដែលមានការផ្លាស់ប្តូរ ។

- ការកើតឡើងនូវកម្មវិធីគោលនយោបាយថ្មីរបស់រាជរដ្ឋាភិបាលៈ ករណីនេះ ចាំបាច់ត្រូវរៀបចំគោលបំណងគោលនយោបាយបន្ថែមទៀតដើម្បីចូលរួមចំណែកអនុវត្តកម្មវិធីគោលនយោបាយថ្មីរបស់រាជរដ្ឋាភិបាល ។
- ភាពគ្រប់គ្រាន់ និង ប្រសិទ្ធភាពនៃគោលបំណងគោលនយោបាយៈ តើគោលបំណងគោលនយោបាយដែលបានរៀបចំមានភាពគ្រប់គ្រាន់ និងមានប្រសិទ្ធភាព ដែលអាចសម្រេចបាននូវគោលនយោបាយតាមវិស័យរបស់ខ្លួនដែរឬទេ? ប្រសិនបើពិនិត្យឃើញថាគោលបំណងគោលនយោបាយដែលបានរៀបចំមិនអាចសម្រេចបាននូវគោលនយោបាយតាមវិស័យទេនោះ ចាំបាច់ត្រូវរៀបចំកែសម្រួលគោលបំណងគោលនយោបាយឡើងវិញ ។
- ការបញ្ចប់ការអនុវត្តគោលបំណងគោលនយោបាយៈ ប្រសិនបើគោលបំណងគោលនយោបាយណាមួយត្រូវបានអនុវត្តចប់សព្វគ្រប់រួចហើយ គឺត្រូវលុបគោលបំណងគោលនយោបាយនោះចេញពីផែនការយុទ្ធសាស្ត្រថវិកាឆ្នាំបន្ទាប់ទៀត ។

គួរកត់សម្គាល់ថា គោលបំណងគោលនយោបាយមិនងាយនឹងផ្លាស់ប្តូរនៅក្នុងរយៈពេល ១ ឆ្នាំទេ ពីព្រោះវាត្រូវបានរៀបចំឡើងសម្រាប់ចក្ខុវិស័យរយៈពេលវែង (៣-៥ ឆ្នាំ) ។

**<u>ការណែនាំក្នុងការបំពេញតារាង ១.១ នៃឧបសម្ព័ន្ធទី ២ៈ</u>**

- កូលោន **គោលនយោបាយនៅក្នុងយុទ្ធសាស្ត្រចតុកោណ/ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** តម្រូវឱ្យសរសេរនូវរាល់គោលនយោបាយទាំងអស់ដែលមាននៅក្នុងយុទ្ធសាស្ត្រចតុកោណ ដែលត្រូវបានរៀបចំនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ហើយដែលទាក់ទងនឹងមុខងារ និងភារកិច្ចរបស់ខ្លួន ។
- កូលោន **គោលនយោបាយតាមវិស័យ** តម្រូវឱ្យសរសេរនូវរាល់គោលនយោបាយតាមវិស័យរបស់ខ្លួន ដែលមាននៅក្នុងយុទ្ធសាស្ត្រចតុកោណ ហើយដែលត្រូវបានរៀបចំនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។
- កូលោន **គោលបំណងគោលនយោបាយដែលបានរៀបចំនៅក្នុងផែនការយុទ្ធសាស្ត្រថវិកា** តម្រូវឱ្យសរសេរនូវគោលបំណងគោលនយោបាយ ដែលបានរៀបចំនៅក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំមុន ។
- កូលោន **ការវាយតម្លៃ** តម្រូវឱ្យវាយតម្លៃនូវគោលបំណងគោលនយោបាយនីមួយៗដែលបានរៀបចំនៅក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំមុន ប្រសិនបើគោលបំណងគោលនយោបាយណាដែលមិនមានការកែប្រែ គឺត្រូវសរសេរអក្សរ ***នៅមានសុពលភាព*** នៅក្នុងកូលោនវាយតម្លៃនេះក្នុងជួរតែមួយជាមួយនឹងគោលបំណងគោលនយោបាយនោះ ប៉ុន្តែប្រសិនបើគោលបំណងគោល

នយោបាយណាមួយមានការកែប្រែ ឬត្រូវបានបញ្ចប់ការអនុវត្ត (ផ្អែកលើលក្ខណៈវាយតម្លៃដែលបានរៀបរាប់ខាងលើ) គឺ ត្រូវសរសេរអក្សរ ***លែងមានសុពលភាព*** នៅក្នុងកូលោនវាយតម្លៃនេះក្នុងជួរតែមួយជាមួយនឹងគោលបំណងគោលនយោបាយនោះ ។

- កូលោន **ការកែសម្រួល** ប្រសិនបើមានគោលបំណងគោលនយោបាយណាមួយដែលត្រូវកែប្រែ ឬលុបចេញ ឬបង្កើតថ្មី គឺ ត្រូវសរសេរគោលបំណងនយោបាយទាំងនោះ នៅក្នុងកូលោននេះ ក្នុងជួរតែមួយជាមួយនឹងគោលបំណង គោលនយោបាយដែលត្រូវកែសម្រួល ។

## ៣.២ ការត្រួតពិនិត្យ និងវាយតម្លៃកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាព

បន្ទាប់ពីត្រួតពិនិត្យ និងវាយតម្លៃគោលបំណងគោលនយោបាយរួចហើយ គ្រប់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ត្រូវត្រួតពិនិត្យ និងវាយតម្លៃកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពបន្តទៀត ។ ការត្រួតពិនិត្យ និងវាយតម្លៃនេះ ត្រូវផ្តោតទៅលើកត្តាដែលធ្វើឱ្យកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពមានការផ្លាស់ប្តូរ ដែលកត្តាទាំងនោះ គឺៈ

- លទ្ធផលនៃការវាយតម្លៃគោលបំណងគោលនយោបាយៈ ប្រសិនបើមានគោលបំណងគោលនយោបាយដែលត្រូវកែប្រែ ឬលុបចេញ ឬបង្កើតថ្មី នោះចាំបាច់ត្រូវរៀបចំកែសម្រួលកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពឡើងវិញ ដើម្បីឱ្យឆ្លើយតបនឹងគោលបំណងគោលនយោបាយទាំងនោះ ។
- ភាពគ្រប់គ្រាន់ និងស័ក្តិសិទ្ធនៃកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពៈ តើកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពដែលបានរៀបចំនៅក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំមុនមានភាពគ្រប់គ្រាន់ និងស័ក្តិសិទ្ធអាចសម្រេចបាននូវគោលបំណងគោលនយោបាយរបស់ខ្លួនដែរឬទេ? ប្រសិនបើពិនិត្យឃើញថាកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពដែលបានរៀបចំនៅក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំមុនមិនអាចសម្រេចបាននូវគោលបំណងគោលនយោបាយរបស់ខ្លួនទេនោះ ចាំបាច់ត្រូវរៀបចំកែសម្រួលកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពឡើងវិញ ។
- ការបញ្ចប់ការអនុវត្តកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពៈ ប្រសិនបើកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពណាមួយត្រូវបានអនុវត្តចប់សព្វគ្រប់រួចហើយ គឺត្រូវលុបកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពនោះចេញពីផែនការយុទ្ធសាស្ត្រថវិកាឆ្នាំបន្ទាប់ ។

**<u>ការណែនាំក្នុងការបំពេញតារាង ២.១ នៃឧបសម្ព័ន្ធទី ២:</u>**

- កូលោន **កម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពដែលបានរៀបចំនៅក្នុងផែនការយុទ្ធសាស្ត្រថវិកា** តម្រូវឱ្យសរសេរនូវរាល់កម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពដែលបានរៀបចំនៅក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំមុន ។

- កូលោន **ការវាយតម្លៃ** តម្រូវឱ្យវាយតម្លៃនូវកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពដែលបានរៀបចំនៅក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំមុន ប្រសិនបើកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពណាដែលមិនមានការកែប្រែ គឺត្រូវសរសេរអក្សរ ***នៅមានសុពលភាព*** នៅក្នុងកូលោនវាយតម្លៃនេះក្នុងជួរតែមួយជាមួយនឹងកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពនោះ ប៉ុន្តែប្រសិនបើកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពណាមួយមានការកែប្រែ ឬត្រូវបានបញ្ចប់ការអនុវត្ត (ផ្អែកលើលក្ខណៈវាយតម្លៃដែលបានរៀបរាប់ខាងលើ) គឺត្រូវសរសេរអក្សរ ***លែងមានសុពលភាព*** នៅក្នុងកូលោនវាយតម្លៃនេះក្នុងជួរតែមួយជាមួយនឹងកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពនោះ ។
- កូលោន **ការកែសម្រួល** ប្រសិនបើមានកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពណាមួយ ដែលត្រូវកែប្រែ លប់ចេញ ឬបង្កើតថ្មី ដោយផ្អែកលើលទ្ធផលនៃការវាយតម្លៃដូចបានរៀបរាប់ខាងលើ គឺត្រូវសរសេរកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពទាំងនោះ នៅក្នុងកូលោននេះក្នុងជួរតែមួយជាមួយនឹងកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពដែលត្រូវកែសម្រួល ។
- កូលោន **ការពន្យល់** តម្រូវឱ្យពន្យល់លើការកែសម្រួលកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាព ។

## ៣.៣ ការត្រួតពិនិត្យ និងវាយតម្លៃសូចនាករ និងគោលដៅសូចនាករ

### ៣.៣.១ ការត្រួតពិនិត្យ និងវាយតម្លៃសូចនាករ

បន្ទាប់ពីត្រួតពិនិត្យ និងវាយតម្លៃកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពរួចហើយ គ្រប់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ត្រូវរៀបចំត្រួតពិនិត្យ និងវាយតម្លៃសូចនាករបន្តទៀត ។ ការត្រួតពិនិត្យ និងវាយតម្លៃនេះ ត្រូវផ្តោតទៅលើកត្តាដែលធ្វើឱ្យសូចនាករមានការផ្លាស់ប្តូរ ដែលកត្តាទាំងនោះ គឺ:

- ភាពគ្រប់ជ្រុងជ្រោយ: សូចនាករត្រូវតែមានភាពគ្រប់ជ្រុងជ្រោយ និងគ្រប់គ្រាន់ដែលឆ្លើយតបទៅនឹងកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាព និង គោលបំណងគោលគោលនយោបាយដែលបានកំណត់ ។
- មានន័យគ្រប់គ្រាន់ និងងាយយល់: សូចនាករត្រូវមានភាពងាយយល់ និង មានប្រយោជន៍ដល់អ្នកគ្រប់គ្រង និង អ្នកនយោបាយ ។
- ភាពជឿទុកចិត្ត: សូចនាករត្រូវមានទិន្នន័យ និង ព័ត៌មានគ្រប់គ្រាន់ដែលអាចធ្វើជាមូលដ្ឋានបាន
- ភាពសាមញ្ញ: សូចនាករត្រូវមានភាពសាមញ្ញដែលផ្តល់ភាពងាយស្រួលក្នុងការគណនា និង បកស្រាយ ។
- ភាពត្រឹមត្រូវ: សូចនាករត្រូវមានភាពគ្រប់គ្រាន់ដែលធានាបាននូវសុក្រឹត្យភាពនៃការវាយតម្លៃអំពីលទ្ធផលក្នុងឆ្នាំ និងលទ្ធផលចុងក្រោយ ។
- ភាពផ្ទៀងផ្ទាត់: សូចនាករត្រូវតែមានព័ត៌មានដែលអាចធ្វើការផ្ទៀងផ្ទាត់ និងត្រួតពិនិត្យបាន ។

- ប្រសិទ្ធភាពៈ ការប្រមូលទិន្នន័យដែលទាក់ទងនឹងសូចនាករត្រូវតែចំណាយតិច ហើយបានទាន់ពេលវេលា ។
- លទ្ធផលនៃការវាយតម្លៃកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពៈ ប្រសិនបើមានកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពដែលត្រូវកែប្រែ ឬលប់ចេញ ឬបង្កើតថ្មី នោះចាំបាច់ត្រូវរៀបចំកែសម្រួលសូចនាករឡើងវិញ ដើម្បីឱ្យឆ្លើយតបនឹងកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពទាំងនោះ ។
- ការបញ្ចប់ការអនុវត្តសូចនាករៈ ប្រសិនបើគោលដៅសូចនាករលទ្ធផលចុងក្រោយណាមួយត្រូវបានអនុវត្តសម្រេចបានជាស្ថាពរ គឺត្រូវលប់សូចនាករនោះចេញពីផែនការយុទ្ធសាស្ត្រថវិកាឆ្នាំបន្ទាប់ទៀត ។

**<u>ការណែនាំក្នុងការបំពេញតារាង ៣.១ នៃឧបសម្ព័ន្ធទី ២ៈ</u>**

- កូលោន **សូចនាករដែលបានរៀបចំនៅក្នុងផែនការយុទ្ធសាស្ត្រថវិកា** តម្រូវឱ្យសរសេរនូវរាល់សូចនាករដែលបានរៀបចំនៅក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំមុន ។
- កូលោន **ការវាយតម្លៃ** តម្រូវឱ្យវាយតម្លៃនូវសូចនាករដែលបានរៀបចំនៅក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំមុន ប្រសិនបើសូចនាករណា ដែលមិនមានការកែប្រែ គឺត្រូវសរសេរអក្សរ ***នៅមានសុពលភាព*** នៅក្នុងកូលោនវាយតម្លៃនេះ ក្នុងជួរតែមួយជាមួយនឹងសូចនាករនោះ ប៉ុន្តែប្រសិនបើសូចនាករណាមួយមានការកែប្រែ ឬត្រូវបានបញ្ចប់ការអនុវត្ត (ផ្អែកលើលក្ខណៈវាយតម្លៃដែលបានរៀបរាប់ខាងលើ) គឺត្រូវសរសេរអក្សរ ***លែងមានសុពលភាព*** នៅក្នុងកូលោនវាយតម្លៃនេះក្នុងជួរតែមួយជាមួយនឹងសូចនាករនោះ ។
- កូលោន **ការកែសម្រួល** ប្រសិនបើមានសូចនាករណាមួយដែលត្រូវកែប្រែ លប់ចេញ ឬបង្កើតថ្មី ដោយផ្អែកលើលទ្ធផលនៃការវាយតម្លៃដូចបានរៀបរាប់ខាងលើ គឺ ត្រូវសរសេរសូចនាករទាំងនោះ នៅក្នុងកូលោននេះ ក្នុងជួរតែមួយជាមួយនឹងសូចនាករដែលត្រូវកែសម្រួល ។
- កូលោន **ការពន្យល់** តម្រូវឱ្យពន្យល់លើការកែសម្រួលសូចនាករ ។

## ៣.៣.២ ការត្រួតពិនិត្យ និងវាយតម្លៃគោលដៅសូចនាករ

បន្ទាប់ពីត្រួតពិនិត្យ និងវាយតម្លៃសូចនាកររួចហើយ គ្រប់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ត្រូវរៀបចំត្រួតពិនិត្យ និងវាយតម្លៃគោលដៅសូចនាករបន្តទៀត ។ ការត្រួតពិនិត្យ និងវាយតម្លៃនេះ គឺត្រូវធ្វើជាពីរជំហានដូចខាងក្រោមៈ

**ជំហានទី ១:** ត្រូវវាយតម្លៃលើលទ្ធផលសម្រេចបានធៀបនឹងគោលដៅសូចនាករដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំមុន ដើម្បីកំណត់ពីភាពប្រាកដនិយមនៃគោលដៅសូចនាករដែលបានកំណត់ក្នុងន័យឈានទៅកែសម្រួលគោលដៅសូចនាករឡើងវិញសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំបន្ទាប់ ។

**ជំហានទី ២:** ត្រូវផ្តោតទៅលើកត្តាដែលធ្វើគោលដៅសូចនាករមានការផ្លាស់ប្តូរ ដែលកត្តាទាំងនោះ គឺ:

- លទ្ធផលនៃការវាយតម្លៃសូចនាករៈ ប្រសិនបើមានសូចនាករដែលត្រូវកែប្រែ ឬលប់ចេញ ឬបង្កើតថ្មី នោះចាំបាច់ត្រូវរៀបចំកែសម្រួលគោលដៅសូចនាករឡើងវិញដើម្បីឱ្យឆ្លើយតបនឹងសូចនាករទាំងនោះ ។
- លទ្ធផលនៃការវាយតម្លៃលទ្ធផលសម្រេចបានធៀបនឹងគោលដៅសូចនាករដែលបានកំណត់ៈ ត្រូវផ្អែកលើលទ្ធផលសម្រេចបានក្នុងឆ្នាំមុនដើម្បីកំណត់អំពីភាពងាយស្រួល និងភាពលំបាកក្នុងការសម្រេចបាននូវគោលដៅដែលបានកំណត់ ក្នុងគោលបំណងឈានទៅកែសម្រួលគោលដៅឡើងវិញ ដើម្បីសម្រេចឱ្យបាននូវគោលបំណងគោលនយោបាយដែលបានកំណត់ ។
- លទ្ធផលនៃការវាយតម្លៃការអនុវត្តចំណាយៈ ប្រសិនបើទំនិញ ឬសេវាមួយមិនត្រូវបានអនុវត្តក្នុងឆ្នាំ វានឹងធ្វើឱ្យប៉ះពាល់ដល់ការសម្រេចបាននូវគោលដៅសូចនាករដែលបានកំណត់ ដែលនឹងនាំឱ្យមានការកំណត់គោលដៅសូចនាករឡើងវិញសម្រាប់ឆ្នាំបន្ទាប់ ។

**ការណែនាំក្នុងការបំពេញតារាង ៣.២ នៃឧបសម្ព័ន្ធទី ២:**

- កូលោន **សូចនាករដែលបានរៀបចំនៅក្នុងផែនការយុទ្ធសាស្ត្រថវិកា** តម្រូវឱ្យសរសេរនូវរាល់សូចនាករដែលបានរៀបចំនៅក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំមុន ។
- កូលោន **គោលដៅឆ្នាំ.......** តម្រូវឱសរសេរនូវរាល់គោលដៅសូចនាករដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំមុន ហើយត្រូវសរសេរគោលដៅសូចនាករនីមួយៗឱ្យត្រូវជួរគ្នានឹងសូចនាករដែលបានរៀបចំនៅក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំមុនដែរ ។
- កូលោន **លទ្ធផល** តម្រូវឱ្យសរសេរនូវរាល់លទ្ធផលដែលសម្រេចបានក្នុងឆ្នាំមុនរបស់គោលដៅសូចនាករនីមួយៗ ហើយត្រូវសរសេរលទ្ធផលគោលដៅសូចនាករនីមួយៗឱ្យត្រូវជួរគ្នានឹងគោលដៅសូចនាករដែលបានកំណត់ ។
- កូលោន **កែសម្រួល** ប្រសិនបើមានគោលដៅសូចនាករណាដែលត្រូវកែសម្រួល ឬលប់ចេញ ឬបង្កើតថ្មី ដោយផ្អែកលើលទ្ធផលនៃការវាយតម្លៃទាំងពីរជំហានដូចបានរៀបរាប់ខាងលើ នោះចាំបាច់ត្រូវសរសេរគោលដៅសូចនាករដែលត្រូវកែសម្រួល និងគោលដៅសូចនាករដែលត្រូវបង្កើតថ្មីនៅក្នុងកូលោននេះ ។

- កូលោន **ការពន្យល់** តម្រូវឱ្យពន្យល់ពីគោលដៅសូចនាករដែលត្រូវកែសម្រួល ឬលប់ចេញ ឬបង្កើតថ្មី ។

## ៣.៤ ការត្រួតពិនិត្យ និងវាយតម្លៃលើការកំណត់ធនធាន

### ៣.៤.១ ការត្រួតពិនិត្យ និងវាយតម្លៃតម្រូវការចំណាយ

គ្រប់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ត្រូវរៀបចំត្រួតពិនិត្យ និងវាយតម្លៃតម្រូវការចំណាយ ហើយការត្រួតពិនិត្យ និងវាយតម្លៃនេះ ត្រូវផ្តោតទៅលើកត្តាដែលធ្វើឱ្យតម្រូវការចំណាយមានការផ្លាស់ប្តូរ ដែលកត្តាទាំងនោះ គឺៈ

- លទ្ធផលនៃការវាយតម្លៃគោលបំណងគោលនយោបាយ
- លទ្ធផលនៃការវាយតម្លៃកម្មវិធី ឬ/នឹងយុទ្ធសាស្ត្រអាទិភាព
- លទ្ធផលនៃការវាយតម្លៃសូចនាករ
- លទ្ធផលនៃការវាយតម្លៃគោលដៅសូចនាករ
- លទ្ធផលនៃការអនុវត្តចំណាយជាក់ស្តែង
- ការខកខាននៃការអនុវត្តចំណាយ
- ការខកខាននៃការផ្តល់ថវិកាដោយដៃគូអភិវឌ្ឍន៍
- កំហុសឆ្គងនៅក្នុងការប៉ាន់ស្មានគម្រោង ឬឯកតាថ្លៃ
- កត្តាផ្សេងៗទៀត ដូចជា ការប្រែប្រួលកំណើនសេដ្ឋកិច្ច អត្រាអតិផរណាខ្ពស់ និង ការកើតឡើងនូវគ្រោះធម្មជាតិ ដែលជះឥទ្ធិពលអវិជ្ជមានដល់ការអនុវត្តចំណាយ ក៏ដូចជាការអនុវត្តកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាព ។

**<u>ការណែនាំក្នុងការបំពេញតារាង ៤.១ នៃឧបសម្ព័ន្ធទី ២:</u>**

- កូលោន **គោលបំណងគោលនយោបាយ/កម្មវិធី/យុទ្ធសាស្ត្រអាទិភាព/ប្រភេទចំណាយ** តម្រូវឱ្យសរសេរឈ្មោះគោលបំណងគោលនយោបាយជាមួយនឹងកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាព ទៅតាមប្រភេទចំណាយចរន្ត និង មូលធន ។ ចំណាយចរន្តត្រូវចែកចេញជាចំណាយបន្ទុកបុគ្គលិក និង ក្រៅពីបន្ទុកបុគ្គលិក ។ ចំណាយមូលធនចែកចេញជា គម្រោងវិនិយោគ មូលនិធិបដិភាគដោយថវិការដ្ឋក្នុងការអនុវត្តគម្រោង មូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ និង ជំនួយបច្ចេកទេស ។

- កូលោន **ផែនការយុទ្ធសាស្ត្រថវិកា** តម្រូវឱ្យបញ្ចូលនូវចំនួនឥណទានដែលបានស្នើនៅក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំមុន ទៅតាមប្រភពហិរញ្ញប្បទាន គឺថវិការដ្ឋ ថវិកាដៃគូអភិវឌ្ឍន៍ និងពីប្រភពផ្សេងៗទៀត ។
- កូលោន **ច្បាប់ហិរញ្ញវត្ថុ** តម្រូវឱ្យបញ្ចូលនូវចំនួនឥណទានដែលបានអនុម័តដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំមុន ទៅតាមប្រភពហិរញ្ញប្បទាន គឺថវិការដ្ឋ ថវិកាដៃគូអភិវឌ្ឍន៍ និងពីប្រភពផ្សេងៗទៀត ។
- កូលោន **អនុវត្ត** តម្រូវឱ្យបញ្ចូលនូវចំនួនឥណទានដែលបានអនុវត្តជាក់ស្តែងសម្រាប់ការគ្រប់គ្រងឆ្នាំមុន ទៅតាមប្រភពហិរញ្ញប្បទាន គឺថវិការដ្ឋ ថវិកាដៃគូអភិវឌ្ឍន៍ និងពីប្រភពផ្សេងៗទៀត ។
- កូលោន **ការពន្យល់** តម្រូវឱ្យពន្យល់អំពីការអនុវត្តធៀបនឹងច្បាប់ហិរញ្ញវត្ថុ ឧទាហរណ៍ការអនុវត្តបានទាបជាងច្បាប់ហិរញ្ញវត្ថុដោយបុព្វហេតុអ្វី និង ការអនុវត្តបានខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុដោយបុព្វហេតុអ្វី ។

## ៣.៤.២ ការត្រួតពិនិត្យ និងវាយតម្លៃការគ្រោងចំណូល

គ្រប់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ដែលមានប្រភពចំណូលត្រូវរៀបចំត្រួតពិនិត្យ និងវាយតម្លៃការគ្រោងចំណូល ហើយការត្រួតពិនិត្យ និងវាយតម្លៃនេះ ត្រូវផ្តោតទៅលើកត្តាដែលធ្វើឱ្យការគ្រោងចំណូលមានការផ្លាស់ប្តូរ ដែលកត្តាទាំងនោះ គឺ:

- លទ្ធផលនៃការអនុវត្តចំណូលជាក់ស្តែង
- ការប្រែប្រួលនូវកំណើនសេដ្ឋកិច្ច
- ការប្រែប្រួលនូវអត្រាអតិផរណា
- ការកែប្រែនូវការអនុវត្តច្បាប់ បទប្បញ្ញត្តិ និង បទបញ្ជារបស់រាជរដ្ឋាភិបាល
- កំហុសឆ្គងនៅក្នុងការគ្រោងចំណូល ឬកំហុសឆ្គងក្នុងការកំណត់យកមូលដ្ឋានគិតចំណូល
- កត្តាផ្សេងៗទៀត ដូចជា កត្តាពីខាងក្រៅដែលអាចជះឥទ្ធិពលដល់សេដ្ឋកិច្ចក្នុងស្រុក គ្រោះធម្មជាតិ ជាដើម ។

**<u>ការណែនាំក្នុងការបំពេញតារាង ៤.២ នៃឧបសម្ព័ន្ធទី ២:</u>**

- កូលោន **ប្រភេទចំណូល** តម្រូវឱ្យសរសេរនូវប្រភពចំណូលដែលស្ថិតក្រោមការគ្រប់គ្រង និងប្រមូលដោយក្រសួង-ស្ថាប័ន និង មន្ទីរជំនាញរាជធានី-ខេត្ត ដោយចែកចេញជាពីរប្រភេទ គឺចំណូលពីប្រភពក្នុងស្រុក និងចំណូលពីប្រភពខាងក្រៅ ។ ចំណូលពីប្រភពក្នុងស្រុក រួមមានចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធ និង ចំណូលមូលធនក្នុងស្រុក ដែលជាប្រភព

ចំណូលផ្ទាល់របស់ ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញរាជធានី-ខេត្ត ។ ចំណូលពីប្រភពខាងក្រៅ ជាប្រភេទចំណូលមូលធន ដែលទទួលបានពីដៃគូអភិវឌ្ឍន៍ ហើយមានពីរប្រភេទ គឺគម្រោងវិនិយោគ និងជំនួយបច្ចេកទេស ។ ប្រភេទចំណូលនេះ គឺត្រូវលំអិតទៅតាមឈ្មោះកម្មវិធី ឬគម្រោងនីមួយៗ និងទៅតាមប្រភេទគម្រោងវិនិយោគ និង ជំនួយបច្ចេកទេស ។

- កូលោន **ផែនការយុទ្ធសាស្ត្រថវិកា** តម្រូវឱ្យបញ្ចូលនូវចំនួនឥណទានដែលបានគ្រោងនៅក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំមុន ។
- កូលោន **ច្បាប់ហិរញ្ញវត្ថុ** តម្រូវឱ្យបញ្ចូលនូវចំនួនឥណទានដែលបានអនុម័តដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំមុន ។
- កូលោន **អនុវត្ត** តម្រូវឱ្យបញ្ចូលនូវចំនួនឥណទានដែលបានអនុវត្តជាក់ស្តែងសម្រាប់ការគ្រប់គ្រងឆ្នាំមុន ។
- កូលោន **ការពន្យល់** តម្រូវឱ្យពន្យល់អំពីការអនុវត្តធៀបនឹងច្បាប់ហិរញ្ញវត្ថុ ឧទាហរណ៍ការអនុវត្តបានទាបជាងច្បាប់ហិរញ្ញវត្ថុដោយបុព្វហេតុអ្វី និង ការអនុវត្តបានខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុដោយបុព្វហេតុអ្វី ។

# ផ្នែកទី ៤៖
# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី ១: ទម្រង់ និងបែបបទសម្រាប់រៀបចំផែនការយុទ្ធសាស្ត្រថវិកា

# ផែនការយុទ្ធសាស្ត្រថវិកា

# សម្រាប់ឆ្នាំ n+1 ឆ្នាំ n+2 និង ឆ្នាំ n+3

# របស់ក្រសួង-ស្ថាប័ន ឬមន្ទីរជំនាញរាជធានី-ខេត្ត.........

## I. សេចក្តីផ្តើម

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................

## II. គោលបំណងគោលនយោបាយ

ដើម្បីរួមចំណែកអនុវត្តគោលនយោបាយតាមវិស័យ ដែលមាននៅក្នុង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិបច្ចុប្បន្នកម្មឆ្នាំ ២០០៩-២០១៣** ដែលជាយុទ្ធសាស្ត្រដើម្បីអនុវត្ត **យុទ្ធសាស្ត្រចតុកោណ** ដើម្បី ***កំណើន ការងារ សមធម៌*** និង ***ប្រសិទ្ធភាព*** សំដៅសម្រេចឱ្យបាននូវគោលដៅកាត់បន្ថយភាពក្រីក្រ និង លើកកម្ពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋ ក្រសួង-ស្ថាប័ន ឬមន្ទីរជំនាញ រាជធានី ខេត្ត........មានគោលបំណងគោលនយោបាយដូចខាង ក្រោម:

| គោលបំណងគោលនយោបាយ | ឆ្លើយតបទៅនឹងជ្រុងណាមួយនៃយុទ្ធសាស្ត្រចតុកោណនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ | ស្ថិតនៅក្នុងគោលនយោបាយតាមវិស័យណាមួយនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
|---|---|---|
| ទី១:................................. | | |
| ទី២:................................. | | |
| ........................................... | | |

## III. កម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាព

ដើម្បីអនុវត្តគោលបំណងគោលនយោបាយខាងលើអោយទទួលបានជោគជ័យ ក្រសួង-ស្ថាប័ន ឬមន្ទីរជំនាញរាជធានី-ខេត្ត បានរៀបចំកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាព ដែលមានដូចខាងក្រោម:

## តារាង ៣.១: កម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាព

គិតជាលានរៀល

| **គោលបំណង គោលនយោបាយ** | **កម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាព** | រយៈពេលអនុវត្ត | តម្រូវការឥណទានសរុប | ប៉ាន់ស្មានឥណទានបានអនុវត្តកន្លងមករហូតដល់ឆ្នាំ n | តម្រូវការឥណទានបន្ត |
|---|---|---|---|---|---|
| គោលបំណងគ.ប ទី ១:.................... | ១.១:........................................................................................... | | | | |
| | ១.២:........................................................................................... | | | | |
| | ១.៣:.......................................................................................... | | | | |
| គោលបំណងគ.ប ទី ២:.................... | ២.១:........................................................................................... | | | | |
| | ២.២:........................................................................................... | | | | |
| | ២.៣:.......................................................................................... | | | | |
| គោលបំណងគ.ប ទី ៣:................... | ៣.១:.......................................................................................... | | | | |
| | ៣.២:.......................................................................................... | | | | |
| | ៣.៣:........................................................................................... | | | | |
| ...................................................... | ................................................................................................ | | | | |

## IV. ការកំណត់សូចនាករ និងគោលដៅសូចនាករ

ក្រសួង-ស្ថាប័ន ឬមន្ទីរជំនាញរាជធានី ខេត្ត បានកំណត់នូវសូចនាករ និង គោលដៅសូចនាករ ដើម្បីតាមដានវឌ្ឍនភាព និង សមិទ្ធិផលនៃការអនុវត្តកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពនីមួយៗ ដូចខាងក្រោម:

**តារាង ៤.១: ការកំណត់សូចនាករ និងគោលដៅសូចនាករ**

| កម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាព | ការកំណត់សូចនាករ | | ស្ថានភាពបច្ចុប្បន្ន | | គោលដៅសូចនាករលទ្ធផលក្នុងឆ្នាំ | | | គោលដៅសូចនាករលទ្ធផលចុងក្រោយ |
|---|---|---|---|---|---|---|---|---|
| | សូចនាករលទ្ធផលក្នុងឆ្នាំ | សូចនាករលទ្ធផលចុងក្រោយ | សូចនាករលទ្ធផលក្នុងឆ្នាំ | សូចនាករលទ្ធផលចុងក្រោយ | ឆ្នាំបន្ទាប់ទី ១ n+1 | ឆ្នាំបន្ទាប់ទី ២ n+2 | ឆ្នាំបន្ទាប់ទី ៣ n+3 | |
| ១.១:......................................... | | | | | | | | |
| ១.២:......................................... | | | | | | | | |
| ១.៣:........................................ | | | | | | | | |
| .................................................. | | | | | | | | |
| ២.១:......................................... | | | | | | | | |
| ២.២:......................................... | | | | | | | | |
| ២.៣:........................................ | | | | | | | | |
| .................................................. | | | | | | | | |
| ៣.៣:........................................ | | | | | | | | |

## V. ការកំណត់ធនធាន

## ការគ្រោងតម្រូវការចំណាយ

**តារាង ៥.១: ការគ្រោងតម្រូវការចំណាយ**

ឯកតាគិតជាលានរៀល

| **គោលបំណងគោលនយោបាយ កម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាព ប្រភេទចំណាយ** | **ច្បាប់ហិរញ្ញវត្ថុ ឆ្នាំបច្ចុប្បន្ន n** | | | **គ្រោងតម្រូវការឥណទានសម្រាប់ ឆ្នាំបន្ទាប់ទី ១ (n+1)** | | | **គ្រោងតម្រូវការឥណទានសម្រាប់ ឆ្នាំបន្ទាប់ទី ២ (n+2)** | | | **គ្រោងតម្រូវការឥណទានសម្រាប់ ឆ្នាំបន្ទាប់ទី ៣ (n+3)** | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ថវិការដ្ឋ | ថវិកាដៃគូ អភិវឌ្ឍន៍ | ផ្សេងៗ | ថវិការដ្ឋ | ថវិកាដៃគូ អភិវឌ្ឍន៍ | ផ្សេងៗ | ថវិការដ្ឋ | ថវិកាដៃគូ អភិវឌ្ឍន៍ | ផ្សេងៗ | ថវិការដ្ឋ | ថវិកាដៃគូ អភិវឌ្ឍន៍ | ផ្សេងៗ |
| **សរុបរួម**<br>-សរុបចំណាយចរន្ត<br>បន្ទុកបុគ្គលិក<br>ក្រៅពីបន្ទុកបុគ្គលិក<br>-សរុបចំណាយមូលធន<br>គម្រោងវិនិយោគ<br>បដិភាគរដ្ឋាភិបាល<br>មូលនិធិទ្រទ្រង់ថវិកា<br>ជំនួយបច្ចេកទេស | | | | | | | | | | | | |
| ១. គោលបំណងគ.ប ទី ១<br>-សរុបចំណាយចរន្ត<br>បន្ទុកបុគ្គលិក<br>ក្រៅពីបន្ទុកបុគ្គលិក<br>-សរុបចំណាយមូលធន<br>គម្រោងវិនិយោគ<br>បដិភាគរដ្ឋាភិបាល<br>មូលនិធិទ្រទ្រង់ថវិកា<br>ជំនួយបច្ចេកទេស | | | | | | | | | | | | |
| ១.១: កម្មវិធី-យុទ្ធសាស្ត្រអាទិភាព ទី ១<br>-ចំណាយចរន្ត<br>..............................................................<br>-ចំណាយមូលធន<br>.............................................................. | | | | | | | | | | | | |

**ការគ្រោងចំណូល**

ដើម្បីរួមចំណែកដល់ការខិតខំរបស់រាជរដ្ឋាភិបាលក្នុងការប្រមូលធនធានដើម្បីសំរេចឱ្យបាននូវក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ចដែលបានកំណត់ ក្រសួង-ស្ថាប័ន ឬមន្ទីរជំនាញរាជធានី ខេត្ត បានដាក់ចេញនូវយុទ្ធសាស្ត្រមួយចំនួន ដើម្បីពង្រឹងការប្រមូលចំណូលដូចខាងក្រោម:

ក....................................................

ខ....................................................

គ....................................................

តាមរយៈយុទ្ធសាស្ត្រនេះ ក្រសួង-ស្ថាប័ន ឬមន្ទីរជំនាញរាជធានី ខេត្ត បានគ្រោងចំណូល ដូចខាងក្រោម:

**តារាង ៥.២: ការគ្រោងចំណូល**

ឯកតាគិតជាលានរៀល

| **ប្រភេទចំណូល** | **ច្បាប់ហិរញ្ញវត្ថុ** ឆ្នាំបច្ចុប្បន្ន (n) | **គ្រោង** ឆ្នាំបន្ទាប់ទី ១ (n+1) | **គ្រោង** ឆ្នាំបន្ទាប់ទី ២ (n+2) | **គ្រោង** ឆ្នាំបន្ទាប់ទី ៣ (n+3) |
|---|---|---|---|---|
| សរុបរួម | | | | |
| ១. ចំណូលពីប្រភពក្នុងស្រុក<br>-ចំណូលសារពើពន្ធ<br>-ចំណូលមិនមែនសារពើពន្ធ<br>-ចំណូលមូលធនក្នុងស្រុក | | | | |
| ២. ចំណូលពីប្រភពក្រៅស្រុក (ពីដៃគូអភិវឌ្ឍន៍)<br>- គម្រោង/កម្មវិធី............................<br>+ គម្រោងវិនិយោគ<br>+ ជំនួយបច្ចេកទេស | | | | |

# VI. សេចក្តីសន្និដ្ឋាន

រាជធានីភ្នំពេញ, ថ្ងៃទី............ខែ................ឆ្នាំ...................

រដ្ឋមន្ត្រី

# ឧបសម្ព័ន្ធទី ២៖ ទម្រង់ និងបែបបទសម្រាប់ត្រួតពិនិត្យ និងវាយតម្លៃផែនការយុទ្ធសាស្ត្រថវិកា

## ការត្រួតពិនិត្យ និងវាយតម្លៃផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ...............
## របស់ក្រសួង-ស្ថាប័ន/មន្ទីររាជធានី-ខេត្ត................................

### ១. ការកំណត់គោលបំណងគោលនយោបាយ

**តារាង ១.១៖ ការត្រួតពិនិត្យ និងវាយតម្លៃលើការកំណត់គោលបំណងគោលនយោបាយ**

| គោលនយោបាយនៅក្នុងយុទ្ធសាស្ត្រចតុកោណ/ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ | គោលនយោបាយតាមវិស័យ | គោលបំណងគោលនយោបាយដែលបានរៀបចំនៅក្នុងផែនការយុទ្ធសាស្ត្រថវិកា | ការវាយតម្លៃ | | ការកែសម្រួល |
|---|---|---|---|---|---|
| | | | នៅមានសុពលភាព | លែងមានសុពលភាព | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

## ២. ការរៀបចំកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាព

| តារាង ២.១: ការត្រួតពិនិត្យ និងវាយតម្លៃលើការរៀបចំកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាព | | | | |
|---|---|---|---|---|
| កម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពដែលបានរៀបចំនៅក្នុងផែនការយុទ្ធសាស្ត្រថវិកា | ការវាយតម្លៃ | | ការកែសម្រួល | ការពន្យល់ |
| | នៅមានសុពលភាព | លែងមានសុពលភាព | | |
| | | | | |
| | | | | |
| | | | | |
| | | | | |

## ៣. ការកំណត់សូចនាករ និងគោលដៅសូចនាករ

### ៣.១. ការកំណត់សូចនករ

| តារាង ៣.១: ការត្រួតពិនិត្យ និងវាយតម្លៃលើការកំណត់សូចនាករ | | | | |
|---|---|---|---|---|
| សូចនាករដែលបានរៀបចំនៅក្នុងផែនការយុទ្ធសាស្ត្រថវិកា | ការវាយតម្លៃ | | ការកែសម្រួល | ការពន្យល់ |
| | នៅមានសុពលភាព | លែងមានសុពលភាព | | |
| | | | | |
| | | | | |
| | | | | |
| | | | | |

## ៣.២. ការកំណត់គោលដៅសូចនាករ

| តារាង ៣.២: ការត្រួតពិនិត្យ និងវាយតម្លៃលើការកំណត់គោលដៅសូចនាករ | | | | |
|---|---|---|---|---|
| សូចនាករដែលបានរៀបចំ នៅក្នុងផែនការយុទ្ធសាស្ត្រថវិកា | ការវាយតម្លៃ | | ការកែសម្រួល | ការពន្យល់ |
| | គោលដៅឆ្នាំ...... | លទ្ធផល | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |

## ៤. ការកំណត់ធនធាន

### ៤.១. ការកំណត់តម្រូវការចំណាយ

**តារាង ៤.១: ការត្រួតពិនិត្យ និងវាយតម្លៃលើការកំណត់តម្រូវការចំណាយសម្រាប់ការគ្រប់គ្រងឆ្នាំ........**

ឯកតា:លានរៀល

| **គោលបំណងគោលនយោបាយ កម្មវិធី-យុទ្ធសាស្ត្រអាទិភាព** | **ផែនការយុទ្ធសាស្ត្រថវិកា** | | | | **ច្បាប់ហិរញ្ញវត្ថុ** | | | | **អនុវត្ត** | | | | | **ការពន្យល់** |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ថវិការដ្ឋ | ថវិកាដៃគូ អភិវឌ្ឍន៍ | ផ្សេងៗ | សរុប | ថវិការដ្ឋ | ថវិកាដៃគូ អភិវឌ្ឍន៍ | ផ្សេងៗ | សរុប | %ច្បាប់ | ថវិការដ្ឋ | ថវិកាដៃគូ អភិវឌ្ឍន៍ | ផ្សេងៗ | |
| **សរុបរួម**<br>-សរុបចំណាយចរន្ត<br>បន្ទុកបុគ្គលិក<br>ក្រៅពីបន្ទុកបុគ្គលិក<br>-សរុបចំណាយមូលធន<br>គម្រោងវិនិយោគ<br>បដិភាគរដ្ឋាភិបាល<br>មូលនិធិទ្រទ្រង់ថវិកា<br>ជំនួយបច្ចេកទេស | | | | | | | | | | | | | | |
| ១. គោលបំណងគ.ប ទី ១<br>...............................<br>............................... | | | | | | | | | | | | | | |
| ១.១: កម្មវិធី-យុទ្ធសាស្ត្រអាទិភាព ទី ១<br>...............................<br>............................... | | | | | | | | | | | | | | |
| ១.២: កម្មវិធី-យុទ្ធសាស្ត្រអាទិភាព ទី ២<br>...............................<br>............................... | | | | | | | | | | | | | | |
| ................................................. | | | | | | | | | | | | | | |
| ................................................. | | | | | | | | | | | | | | |
| ................................................. | | | | | | | | | | | | | | |

### ៤.២. ការគ្រោងចំណូល

| តារាង ៤.២: ការត្រួតពិនិត្យ និងវាយតម្លៃលើការគ្រោងចំណូលសម្រាប់ការគ្រប់គ្រងឆ្នាំ.............. ឯកតា:លានរៀល | | | | | |
|---|---|---|---|---|---|
| ប្រភេទចំណូល | ផែនការយុទ្ធសាស្ត្រថវិកា | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | | ការពន្យល់ |
| | | | ទឹកប្រាក់ | %ច្បាប់ | |
| សរុបរួម | | | | | |
| ១. ចំណូលពីប្រភពក្នុងស្រុក<br>- ចំណូលសារពើពន្ធ<br>- ចំណូលមិនមែនសារពើពន្ធ<br>- ចំណូលមូលធនក្នុងស្រុក | | | | | |
| ២. ចំណូលពីប្រភពខាងក្រៅ (ពីដៃគូអភិវឌ្ឍន៍)<br>- គម្រោង/កម្មវិធី.........................<br>+គម្រោងវិនិយោគ<br>+ ជំនួយបច្ចេកទេស | | | | | |

### ៥. បញ្ហាប្រឈម និងអនុសាសន៍កែលម្អលើការរៀបចំផែនការយុទ្ធសាស្ត្រថវិកា

រាជធានីភ្នំពេញ, ថ្ងៃទី...............ខែ....................ឆ្នាំ............

**បានឃើញ និងឯកភាព**

**រដ្ឋមន្ត្រី**

**អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ**